**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការដ្ឋាន**

លេខ: ០៧៩ គ.ជ.ប.អគ្គ

ថ្ងៃពុធ ១កេត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

## គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ស្របតាមបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត ផែនការមេ និងប្រតិទិនការងាររបស់ គ.ជ.ប។

ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ ត្រូវបានបែងចែកជា ៥ ក្រុម ដោយក្រុមនីមួយៗ ទទួលបន្ទុកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមឃុំ សង្កាត់ នៃខេត្តចំនួន ៥ លើកលែងតែក្រុមទី៣ ទទួលបន្ទុកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមឃុំ សង្កាត់ នៃខេត្តចំនួន ៤ និងសង្កាត់ទាំងអស់ នៃរាជធានីភ្នំពេញ។

ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលបានចំណាយពេល ២ ថ្ងៃ គឺនៅថ្ងៃទី១៣ និងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ហើយក្រុមនីមួយៗបានអនុវត្តការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់របស់ខ្លួននៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន នៅទីស្តីការ គ.ជ.ប ។

ជាលទ្ធផល ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ មិនបានរកឃើញកំហុសណាមួយពាក់ព័ន្ធការគណនាតួលេខលទ្ធផលសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយនីមួយៗ ដែលគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) បានបញ្ជាក់ក្នុងក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥ធខ) តារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត (ទ.១១១១) ឡើយ។ ភាគីដែលចូលរួមជាសាក្សីទាំងអស់បានឯកភាព និងពុំមានការតវ៉ា ឬជំទាស់អ្វីនោះទេ។

ការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត កាលពីថ្ងៃទី៥ និងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះ គ.ជ.ប បានធ្វើឡើងដោយផ្អែកលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត បានបញ្ជូនមក ហើយទម្រង់នេះ ត្រូវបានបង្ហោះនៅលើគេហទំព័រ គ.ជ.ប electresult.nec.gov.kh។

អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
អ៊ីមែល៖ info@nec.gov.kh